# ការដាក់របាយការណ៍ជាលាយលក្ខណ៍អក្សរ
# ដោយអង្គការសង្គមស៊ីវិលទៅយន្តការ UPR
## ព័ត៌មានសំរាប់អង្គការសង្គមស៊ីវិល

*កាលបរិច្ឆេទផុតកំណត់សំរាប់ការដាក់របាយការណ៍របស់អង្គការសង្គមស៊ីវិលទៅយន្តការ UPR ជុំទី២ ត្រូវបានកំណត់ត្រឹមថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៣*

## តើព័ត៌មានអ្វីខ្លះ ដែលអង្គការសង្គមស៊ីវិលអាចបញ្ចូលក្នុងរបាយការណ៍?

ក្រោមយន្តការពិនិត្យរបាយការណ៍ជាសកលតាមកាលកំណត់ (UPR) អង្គការសង្គមស៊ីវិល អាចធ្វើរបាយការណ៍ជាលាយលក្ខណ៍អក្សរស្តីពីស្ថានភាពសិទ្ធិមនុស្សនៃរដ្ឋសមាជិកណាមួយរបស់ អ.ស.ប បាន។ ពាក្យថាអង្គការសង្គមស៊ីវិលរួមមាន អ្នកការពារសិទ្ធិមនុស្ស សមាគម អង្គការមិនមែនរដ្ឋាភិបាល វិទ្យាស្ថានបណ្ឌិតសភា និងការស្រាវជ្រាវ ឬមជ្ឈមណ្ឌលអប់រំ អ្នកសារព័ត៌មាន សហគមន៍ សហជីព...។ល។

ដូច្នេះ អង្គការសង្គមស៊ីវិលអាចលើកយកបញ្ហាទាំងឡាយស្ថិតក្រោមកតិកាសញ្ញា និងអនុសញ្ញាអន្តរជាតិនីមួយៗ ព្រមទាំងបញ្ហាពាក់ព័ន្ធណាមួយដែលគ្របដណ្តប់ដោយធម្មនុញ្ញ អ.ស.ប សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស លិខិតុបករណ៍សិទ្ធិមនុស្សដទៃទៀតដែលរដ្ឋនោះជាភាគី ការប្តេជ្ញាចិត្តនិងការសន្យាដោយស្ម័គ្រចិត្តធ្វើឡើងដោយរដ្ឋមួយ និងច្បាប់មនុស្សធម៌អន្តរជាតិដែលកំពុងអនុវត្ត។

## តើរបាយការណ៍របស់អង្គការសង្គមស៊ីវិល ដាក់ជូនយន្តការ UPR មានលក្ខណៈពិសេសអ្វីខ្លះ?

- រាល់របាយការណ៍ធ្វើទៅយន្តការ UPR គឺជារបាយការណ៍សាធារណៈ ទោះជារបាយការណ៍ទាំងនោះ រដ្ឋ អង្គការសហប្រជាជាតិ ឬអង្គការសង្គមស៊ីវិល គឺជាអ្នកបញ្ជូនក្តី។
- របាយការណ៍របស់អង្គការសង្គមស៊ីវិលមិនត្រូវឲ្យលើសពី២.៨១៥ពាក្យ(ប្រហែលជា៥ទំព័រ) សំរាប់របាយការណ៍ដែលធ្វើដោយអង្គការសង្គមស៊ីវិលមួយ និង ៥.៦៣០ពាក្យ (ប្រហែលជា១០ទំព័រ) សំរាប់របាយការណ៍ធ្វើរួមគ្នា។
- ទំព័រគំរប លេខជើងទំព័រ លេខចុងទំព័រ និងឧបសម្ព័ន្ធ នឹងមិនត្រូវបានគិតចូលក្នុងចំនួនពាក្យកំណត់ និងមិនត្រូវបានបញ្ចូលក្នុងកំណត់សង្ខេបនៃព័ត៌មានអ្នកពាក់ព័ន្ធឡើយ។
- របាយការណ៍របស់អង្គការសង្គមស៊ីវិល មិនចាំបាច់ត្រូវគ្របដណ្តប់លើគ្រប់សិទ្ធិទាំងអស់ឡើយ។ ផ្ទុយទៅវិញ គេអាចកំណត់អាទិភាពលើបញ្ហាសិទ្ធិសំខាន់ៗមួយចំនួនបាន។
- របាយការណ៍របស់អង្គការសង្គមស៊ីវិល ដែលគោរពតាមគោលការណ៍ណែនាំផ្នែកបច្ចេកទេសនៃការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស(ការិយាល័យ OHCHR) នឹងត្រូវបានបង្ហោះលើគេហទំព័ររបស់ការិយាល័យ OHCHR។[1]

[1] សូមមើលគេហទំព័រ http://www.ohchr.org/Documents/HRBodies/UPR/TechnicalGuideEN.pdf

កំណាត់សំគាល់សំខាន់ៗ៖

*របាយការណ៍ជាលាយលក្ខណ៍អក្សររបស់អង្គការសង្គមស៊ីវិលដាក់ជូនយន្តការ UPR មិនអាចធ្វើជាលក្ខណៈអនាមិក ឬជាសំងាត់បានឡើយ។ ឈ្មោះអង្គការដែលផ្ញើព័ត៌មាន និងរបាយការណ៍ជាលាយលក្ខណ៍អក្សរ នឹងមាននៅលើគេហទំព័រអនឡាញ។ អាស្រ័យហេតុនេះ ឯកសារយោងលើករណីបុគ្គលម្នាក់ៗ អាចនឹងត្រូវបានដាក់បញ្ចូលក្នុងរបាយការណ៍ ប្រសិនបើសុវត្ថិភាព និងសុខមាលភាពរបស់បុគ្គលសាម៉ីនោះ មិនប្រឈមនឹងហានិភ័យ។*

*ប្រសិនជាមានការភ័យខ្លាចកើតមានការសងសឹក អង្គការសង្គមស៊ីវិលជាតិនោះ អាចផ្ញើព័ត៌មាននោះ តាមរយៈអង្គការ NGO អន្តរជាតិណាមួយបាន។*

- លេខាធិការដ្ឋានការិយាល័យ OHCHR នឹងមិនរៀបចំសេចក្តីព្រាងរបាយការណ៍ទាំងឡាយឡើងវិញឡើយ។ ហេតុដូច្នេះ សេចក្តីដកស្រង់ចេញពីរបាយការណ៍របស់អង្គការសង្គមស៊ីវិល អាចត្រូវបានជ្រើសសម្រាំងដោយការិយាល័យ OHCHR និងដាក់បញ្ចូលទៅក្នុង**កំណត់សង្ខេបនៃព័ត៌មានរបស់ដៃគូការងារពាក់ព័ន្ធ** (ដែលគេស្គាល់ថា របាយការណ៍សង្ខេបរបស់ការិយាល័យ OHCHR)។ កំណត់សង្ខេបនេះ គឺជារបាយការណ៍មួយក្នុងចំណោមរបាយការណ៍ចំនួនបី[2] ដែលជាមូលដ្ឋានសំរាប់ការពិនិត្យរបាយការណ៍របស់រដ្ឋមួយ។
- អង្គការសង្គមស៊ីវិលត្រូវបញ្ជូនរបាយការណ៍របស់ខ្លួន ឲ្យបានមុនរដ្ឋបញ្ជូនរបាយការណ៍ជាតិរបស់ខ្លួន។ អាស្រ័យហេតុនេះ អង្គការសង្គមស៊ីវិល មិនមានលទ្ធភាពអាចឆ្លើយតបនឹងទស្សនៈរបស់រដ្ឋឡើយ ប៉ុន្តែពួកគេមានឱកាសគូសបញ្ជាក់អំពីបញ្ហាដែលត្រូវពិភាក្សា។
- អង្គការសង្គមស៊ីវិល ត្រូវបានលើទឹកចិត្តឲ្យបញ្ចូលសមិទ្ធិផលទាំងឡាយដែលសម្រេចបាន ការអនុវត្តល្អៗ បញ្ហាប្រឈម និងឧបសគ្គរបស់រដ្ឋ ក្នុងរបាយការណ៍របស់ខ្លួន (ប្រសិនជាអាចធ្វើបាន) និងព័ត៌មានស្តីពីការអនុវត្តអនុសាសន៍ UPR ដែលបានទទួលយក ចាប់តាំងពីពេលពិនិត្យរបាយការណ៍លើកមុន។

---

[2] ការពិនិត្យរបាយការណ៍UPR របស់រដ្ឋមួយត្រូវផ្អែកលើរបាយការណ៍ធំៗចំនួនបី៖ របាយការណ៍ជាតិរបស់រដ្ឋ (ប្រហែលជា២០ទំព័រ) កម្រងព័ត៌មានរបស់ អ.ស.ប ស្តីពីរដ្ឋ (ប្រហែលជា១០ទំព័រ) រាប់ទាំងសេចក្តីសង្កេតសន្និដ្ឋានរបស់ស្ថាប័នសន្ធិសញ្ញា និងកំណត់សង្ខេបនៃព័ត៌មានអ្នកពាក់ព័ន្ធដទៃទៀត (ប្រហែលជា១០ទំព័រ) ផ្អែកលើរបាយការណ៍ជាលាយលក្ខណ៍អក្សររបស់អង្គការសង្គមស៊ីវិល ស្ថាប័នជាតិសិទ្ធិមនុស្ស (NHRIs) អ្នកការពារសិទ្ធិមនុស្ស គ្រឹះស្ថានសិក្សា ombudspersons និងអង្គការនានាថ្នាក់តំបន់ដែលបានរៀបចំឡើងដោយការិយាល័យ OHCHR ។

**តើត្រូវធ្វើដូចម្ដេច ដើម្បីធានាថាព័ត៌មានរបស់អង្គការសង្គមស៊ីវិល ត្រូវបានបញ្ចូលទៅក្នុងរបាយការណ៍សង្ខេបរបស់ការិយាល័យ OHCHR?**

*ដើម្បីធានាឲ្យការបញ្ជូនមានលក្ខណៈប្រាកដប្រជា និងជឿទុកចិត្តបាន៖*

ការិយាល័យ OHCHR មិនមានពេលពិនិត្យមើលព័ត៌មានដែលអង្គការសង្គមស៊ីវិលបានផ្ដល់ឲ្យទេ ដូច្នេះ ពួកគេត្រូវតែមានជំនឿចិត្តលើព័ត៌មានដែលពួកគេទទួល។ ការបញ្ជូនរបាយការណ៍រួមគ្នាមួយបង្កើននូវភាពជឿទុកចិត្ត និងភាពច្បាស់លាស់នៃព័ត៌មានរបស់អង្គការសង្គមស៊ីវិល ដែលជួយបង្កើនលទ្ធភាពក្នុងការដាក់បញ្ចូលព័ត៌មានទាំងនោះ ទៅក្នុងរបាយការណ៍សង្ខេបរបស់ការិយាល័យ OHCHR។ ជាពិសេស សំរាប់អង្គការសង្គមស៊ីវិលជាតិដែលការិយាល័យ OHCHR អាចមិនស្គាល់។

អង្គការសង្គមស៊ីវិល គួរប្រើភាសាបច្ចេកទេស និងឧទាហរណ៍ផ្សេងៗ ព្រោះវាអាចបង្ហាញថា របាយការណ៍របស់អង្គការសង្គមស៊ីវិល បានផ្អែកលើព័ត៌មានជំបូង។

*ផ្ដល់ព័ត៌មានក្នុងទម្រង់មួយដែលការិយាល័យ OHCHR អាចងាយស្រួលប្រើប្រាស់៖*

ពុំមានទម្រង់ជាផ្លូវការណាសំរាប់ការដាក់របាយការណ៍របស់អង្គការសង្គមស៊ីវិលទៅយន្តការ UPR ទេ។

ដើម្បីបង្កើនឱកាសទទួលបានព័ត៌មានដែលត្រូវបញ្ចូលក្នុងរបាយការណ៍សង្ខេប អង្គការសង្គមស៊ីវិល គួរផ្ដល់ព័ត៌មានអំពីបញ្ហានីមួយៗដូចតទៅ៖

១) សេចក្ដីថ្លែងការណ៍ទូទៅដែលគូសបញ្ជាក់អំពីបញ្ហានោះ

២) ឧទាហរណ៍គាំទ្រអំណះអំណាង និង

៣) អនុសាសន៍ផ្សេងៗ។

ជារឿយៗ ការិយាល័យ OHCHR ប្រើប្រាស់សេចក្ដីថ្លែងការណ៍ទូទៅ និងអនុសាសន៍ផ្សេងៗក្នុងរបាយការណ៍របស់ខ្លួន។ ទន្ទឹមនឹងនេះ ឧទាហរណ៍កម្រនឹងបញ្ចូលក្នុងរបាយការណ៍សង្ខេបណាស់ ដោយសារថា ឧទាហរណ៍វាគ្រាន់តែដើម្បីបង្ហាញថា ព័ត៌មានរបស់អង្គការសង្គមស៊ីវិល អាចជឿទុកចិត្ត និងយកជាការបាន។

**តើព័ត៌មានបែបណាខ្លះដែលអង្គការស៊ីវិលគួរតែបញ្ចូល?**

*សំរាប់ដំណើរការ UPR ជុំទី២ នេះ អង្គការសង្គមស៊ីវិលគួរតែផ្ដោតទិន្ន័យរបស់ខ្លួនដូចតទៅ៖*

- គូសបញ្ជាក់អំពីបញ្ហាជាកង្វល់ធំៗក្នុងរដ្ឋ ដែលបាននិងកំពុងកើតមានក្នុងអំឡុងពេល៤ឆ្នាំកន្លះកន្លងមក រាប់ទាំងបញ្ហាដែលទើបកើតមាន ឬបញ្ហាដែលត្រូវការដាក់សម្ពាធពីអន្តរជាតិ។
- បញ្ចូលព័ត៌មានស្ដីពីការអនុវត្តអនុសាសន៍ដែលបានទទួលយក នៅក្នុងជុំ ***UPR*** កន្លងមក។

*បន្ថែមលើនេះទៀត អង្គការសង្គមស៊ីវិល ត្រូវបានស្នើសុំឲ្យ៖*

- និយាយយោងលិខិតុបករណ៍សិទ្ធិមនុស្ស បទដ្ឋានគតិយុត្តជាតិ។ល។ សំរាប់បញ្ហានីមួយៗដែលបានលើកឡើង។

- សេចក្តីថ្លែងការណ៍ទូទៅចង្អុលបង្ហាញពីបញ្ហាអ្វីមួយគួរតែរៀបរាប់ដោយសង្ខេប ហើយប្រសិនជាអាចធ្វើបាន គួរតែបញ្ចូលសមិទ្ធិផល និងការអនុវត្តល្អៗរបស់រដ្ឋ។
- ត្រូវបញ្ជាក់ឲ្យច្បាស់លាស់ ដោយចំៗ ដែលមានគោលដៅតម្រង់ទិស (មានន័យថាអាចអនុវត្តបានក្នុងរយៈពេល ៤ឆ្នាំកន្លះបន្ទាប់) និងងាយស្រួលឃ្លាំមើលអនុសាសន៍ដែលដាក់ឲ្យរដ្ឋអនុវត្ត។ សំខាន់ត្រូវយកចិត្តទុកដាក់ប្រយ័ត្នប្រយែងពាក្យពេចន៍ក្នុងអនុសាសន៍។ ផលប៉ះផលរបស់វាអាចនឹងផ្សេងគ្នា ប្រសិនជាអនុសាសន៍គឺ "ដើម្បីផ្តល់សច្ចាប័ន" លើ សន្ធិសញ្ញាមួយ ឬ "ដើម្បីពិចារណាលើការផ្តល់សច្ចាប័នលើសន្ធិសញ្ញាមួយ" ។
- របាយការណ៍ជាលាយលក្ខណ៍អក្សរ មិនគួរបញ្ចូលព័ត៌មានបន្ទាប់បន្សំឡើយ (លើកលែងតែករណីដែលព័ត៌មាននោះ គឺជាអំណះអំណាងដែលគាំទ្រជាក់ច្បាស់ចំពោះព័ត៌មានដើមដំបូង)។ អង្គហេតុ និងភស្តុតាងដែលគាំទ្រដល់អនុសាសន៍ និងបញ្ហាអាទិភាពដែលបានកំណត់ អាចត្រូវបានភ្ជាប់ជាឧបសម្ព័ន្ធនៃរបាយការណ៍នោះ សំរាប់ធ្វើជាឯកសារយោង។
- ត្រូវកំណត់យកជាអតិបរមាពី៥–១០បញ្ហាគន្លឹះ ក្នុងប្រទេសនោះ (យកល្អ ក្នុងមួយទំព័រត្រូវសរសេរតែ១–២បញ្ហាបានហើយ)។

**តើសង្គមស៊ីវិលគួរធ្វើរបាយការណ៍រៀងៗខ្លួន ឬធ្វើរបាយការណ៍រួមគ្នា?**

របាយការណ៍ទាំងពីរប្រភេទនេះ ត្រូវបានពិចារណាដោយការិយាល័យ OHCHR ប៉ុន្តែរបាយការណ៍នីមួយៗ មានផលល្អ និងផលអាក្រក់របស់វា។

*របាយការណ៍របស់អង្គការសង្គមស៊ីវិលដែលធ្វើរួមគ្នា៖*

- បង្កើនភាពច្បាស់លាស់ និងភាពជឿទុកចិត្តបាននៃរបាយការណ៍របស់អង្គការសង្គមស៊ីវិល និងឱកាសដែលព័ត៌មា ភាគច្រើន ត្រូវបានការិយាល័យ OHCHR បញ្ចូលទៅក្នុងរបាយការណ៍សង្ខេបរបស់ខ្លួន។
- ផ្តល់លទ្ធភាពឲ្យអង្គការសង្គមស៊ីវិល ដែលធនធានមានកំរិត អាចចូលរួមក្នុងយន្តការ UPR ដោយមិនគិតពីទំហំ និងសមត្ថភាពរបស់ខ្លួនឡើយ។
- ផ្តល់ឱកាសពង្រឹងកិច្ចសហប្រតិបត្តិការទូលំទូលាយថែមទៀតជាមួយសង្គមស៊ីវិលនៅថ្នាក់ជាតិ ប្រយោជន៍សំរាប់ការតស៊ូមតិ និងឃ្លាំមើលការអនុវត្ត។
- ត្រូវបានលើកទឹកចិត្តដោយការិយាល័យ OHCHR ដោយសារតែវាគ្របដណ្តប់លើបញ្ហាសិទ្ធិមនុស្សជាច្រើន នៅក្នុងប្រទេសមួយ និងឆ្លុះបញ្ចាំងអំពីវិស័យអាទិភាពសំរាប់អង្គការសង្គមស៊ីវិលមួយចំនួន។
- សម្រួលដល់ការតស៊ូមតិនៅថ្នាក់ជាតិ និងនៅទីក្រុងហ្សឺណែវ។

**ឧទាហរណ៍៖** របាយការណ៍រួមគ្នានៃសម្ព័ន្ធអាល់បានី ទាំងអស់គ្នាប្រឆាំងការជួញដូរកុមារ និងភូមិអាល់បានីសង្គ្រោះ កុមារ ត្រូវបានគេនិយាយជាច្រើនលើកច្រើនសារនៅក្នុងរបាយការណ៍សង្ខេបរបស់ OHCHR។ អង្គការសង្គមស៊ីវិល បានប្រើប្រាស់របាយការណ៍នេះ ដើម្បីបញ្ចុះបញ្ចូលរដ្ឋនានា ឲ្យធ្វើអនុសាសន៍ ដោយយកលំនាំតាមសាធារណរដ្ឋអាល់បានី។[3]

[3] ដើម្បីអានរបាយការណ៍របស់ខ្លួន សូមចូលទៅកាន់គេហទំព័រ៖
http://lib.ohchr.org/HRBodies/UPR/Documents/Session6/AL/ATACT_ALB_UPR_S06_2009.pdf

*របាយការណ៍របស់អង្គការសង្គមស៊ីវិល ដែលធ្វើរៀងៗខ្លួន៖*

- ការរៀបចំរបាយការណ៍បែបនេះ អាចនឹងឆាប់រហ័សជាង ដោយសារវាមិនពាក់ព័ន្ធដល់ការចរចាឯកភាពគ្នាលើខ្លឹមសារ អត្ថបទរបាយការណ៍ ជាមួយអង្គការសង្គមស៊ីវិលដទៃផ្សេងទៀត។
- បញ្ចៀសបាននូវតម្រូវការសម្រុះសម្រួលគ្នាលើបញ្ហាគន្លឹះមួយចំនួនដែលអង្គការសង្គមស៊ីវិលមួយចង់លើកឡើង។
- អាចផ្តោតលើបញ្ហាជាក់លាក់មួយឬច្រើន ដែលអាចឲ្យការិយាល័យ OHCHR ស្រួលឃើញច្រើនជាង អំពីបញ្ហាអាទិភាពផ្សេងៗ។
- មានប្រសិទ្ធភាព ប្រសិនជាការិយាល័យ OHCHR ស្គាល់អង្គការរបស់លោក/អ្នក និងមានការជឿទុកចិត្តលើព័ត៌មាន ដែលអ្នកផ្តល់ឲ្យ។

**ឧទាហរណ៍៖** អង្គការគំនិតផ្តួចផ្តើមពិភពលោកដើម្បីបញ្ចប់រាល់ទណ្ឌកម្មលើរូបកាយកុមារ(Global Initiative to End All Corporal Punishment of Children) ធ្វើរបាយការណ៍មួយដែលមានពីរទំព័រ សំរាប់ប្រទេសនីមួយៗ ពិនិត្យលើនីត្យានុកូលភាពនៃទណ្ឌកម្មលើរូបកាយ ហើយជានិច្ចកាលត្រូវបានបរិយាយក្នុងរបាយការណ៍សង្ខេបរបស់ការិយាល័យ OHCHR។[4]

**ការណែនាំ៖** *អង្គការសង្គមស៊ីវិល មិនចាំបាច់ត្រូវជ្រើសរើសរវាងការធ្វើរបាយការណ៍រៀងៗខ្លួន ឬការធ្វើរបាយការណ៍រួមគ្នានោះទេ។ ពួកគេអាចរៀបចំធ្វើរបាយការណ៍រៀងៗខ្លួន ហើយចូលរួមក្នុងការធ្វើរបាយការណ៍រួមគ្នា តាមដែលខ្លួនចង់ធ្វើ។ ការនេះគឺស្រេចតែអង្គការសង្គមស៊ីវិល ជាអ្នកសម្រេចថាតើ របាយការណ៍ប្រភេទមួយណាមានប្រសិទ្ធភាពបំផុត ហើយចំណាយពេលវេលាតិចបំផុតក្នុងការទំនាក់ ទំនងប្រាប់ឲ្យដឹងអំពីបញ្ហារបស់ខ្លួន។*

**ព័ត៌មានផ្នែកបច្ចេកទេស**[5]

*១. រចនាបថនៃរបាយការណ៍*

- ចៀសវាងការប្រើពាក្យពេចន៍អត្តនោម័ត ឬដោយការរំជួលចិត្ត។
- **មិនត្រូវ**បញ្ចូលរូបភាព ផែនទី របាយការណ៍ប្រចាំឆ្នាំរបស់អង្គការ ឬរបាយការណ៍ពីអង្គការផ្សេងៗទៀត ជាឧបសម្ព័ន្ធនៃរបាយការណ៍នេះឡើយ។
- **មិនត្រូវ**ប្រើលេខជើងទំព័រច្រើនពេកទេ។

[4] ដើម្បីអានរបាយការណ៍មួយ ក្នុងចំណោមរបាយការណ៍ផ្សេងៗរបស់ខ្លួន សូមចូលទៅកាន់គេហទំព័រ ៖ http://lib.ohchr.org/HRBodies/UPR/Documents/Session9/HN/GIEACPC_EndofCorporalPunishmentofChildren.pdf

[5] ព័ត៌មាននេះ គឺផ្អែកលើគោលការណ៍ណែនាំផ្នែកបច្ចេកទេសរបស់ការិយាល័យ OHCHR។ ដើម្បីអានគោលការណ៍ណែនាំនេះទាំងស្រុង សូមចូលទៅកាន់គេហទំព័រ ៖ http://www.ohchr.org/Documents/HRBodies/UPR/TechnicalGuideEN.pdf

## ២. *រចនាសម្ព័ន្ធនៃរបាយការណ៍*

- បញ្ចូលមួយទំព័រគំរប ដែលកំណត់សំគាល់**អ្នកពាក់ព័ន្ធទាំងអស់** (ក្បាលលិខិត ឈ្មោះ និងពាក្យកាត់ រូបសញ្ញា វិបសាយ។ល។) និងការរៀបរាប់អំពីសកម្មភាពធំៗរបស់អង្គការ/សម្ព័ន្ធ ក៏ដូចជាកាលបរិច្ឆេទនៃការបង្កើតរបស់វា ជាពិសេស ប្រសិនជាអង្គការសង្គមស៊ីវិលនោះកំពុងធ្វើការជាមួយ អ.ស.ប សំរាប់ជាលើកដំបូង។
- បញ្ចូលសេចក្តីផ្តើមប្រតិបត្តិសង្ខេប ស្រង់យកតែចំណុចសំខាន់ៗមកបរិយាយ និង/ឬបង្ហាញពាក្យគន្លឹះ ដើម្បីជួយឲ្យការិយាល័យ OHCHR យល់អំពីថាតើរបាយការណ៍នេះនិយាយពីអ្វី (ឧទា. សិទ្ធិអប់រំ)។
- ការបញ្ជូនរបាយការណ៍ជាលាយលក្ខណ៍អក្សរ ត្រូវធ្វើក្នុងទម្រង់ជា **Word document only** (មានន័យថា មិនត្រូវធ្វើក្នុងទម្រង់ជាឯកសារ PDF) ឡើយ។
- របាយការណ៍ ត្រូវមានបង់លេខកថាខ័ណ្ឌ និងទំព័រ។

## ៣. *ការបញ្ជូនរបាយការណ៍* UPR ៖

- បញ្ជូនរបាយការណ៍ទៅ៖ uprsubmissions@ohchr.org
- បញ្ជូនចំពោះតែប្រទេសមួយប៉ុណ្ណោះ នៅក្នុងរបាយការណ៍អេឡិចត្រូនិក និងសារអ៊ីម៉ែលពាក់ព័ន្ធ។
- ក្នុងចំណងជើងនៃសារអេឡិចត្រូនិក(អ៊ីម៉ែល) ត្រូវមានឈ្មោះសម្ព័ន្ធ/អង្គការសង្គមស៊ីវិល(មេ) ដែលបញ្ជូនរបាយការណ៍រួមគ្នា/វិភាគទាននោះ របៀបនៃការរួមវិភាគទាន (រៀងៗខ្លួន ឬរួមគ្នា) ឈ្មោះប្រទេសដែលស្ថិតក្រោមការពិនិត្យរបាយការណ៍ និងខែ-ឆ្នាំ នៃសម័យប្រជុំ UPR ពាក់ព័ន្ធ ឧទា. *សម្ព័ន្ធសិទ្ធិកុមារ – របាយការណ៍ UPR រួមគ្នា – Cambodia – February 2014* ក្នុងចំណងជើងនៃសារអេឡិចត្រូនិក(អ៊ីម៉ែល)។
- ក្នុងអត្ថបទនៃសារអេឡិចត្រូនិក(អ៊ីម៉ែល) ដែលអមជាមួយរបាយការណ៍នេះ ត្រូវផ្តល់សេចក្តីលំអិតអំពីមន្ត្រីទំនាក់ទំនងដែលពាក់ព័ន្ធ និងកថាខ័ណ្ឌមួយដែលរៀបរាប់អំពីសកម្មភាពការងារធំៗរបស់សម្ព័ន្ធ/អង្គការសង្គមស៊ីវិល កាលបរិច្ឆេទ(ថ្ងៃខែឆ្នាំ) នៃការបង្កើតសម្ព័ន្ធ/អង្គការសង្គមស៊ីវិលនោះ ជាពិសេស ប្រសិនជាសម្ព័ន្ធ/អង្គការសង្គមស៊ីវិលនោះ ទើបនឹងចូលរួមជាលើកដំបូងក្នុងការងាររបស់ អ.ស.ប។
- លេខាធិការដ្ឋាននៃការិយាល័យ OHCHR នឹងបញ្ជាក់ប្រាប់តាមរយៈសារអេឡិចត្រូនិក ពីការទទួលសារ និងរបាយការណ៍របស់អង្គការសង្គមស៊ីវិល។ ដើម្បីរក្សាទុកធ្វើជាតឹកតាងបញ្ជាក់ថា របាយការណ៍នោះ ត្រូវបានបញ្ជូនទាន់ពេលវេលា ត្រូវបន្ថែម "អ៊ីម៉ែលដែលបានអាន" ចំនួនមួយច្បាប់ទៅការិយាល័យ OHCHR និង/ឬរក្សាទុកអត្ថបទចម្លងចំនួន មួយច្បាប់នៃអ៊ីម៉ែលនោះ។
- សំរាប់ជាដំណោះស្រាយចុងក្រោយ ប្រសិនជាការលំបាកផ្នែកបច្ចេកទេសនៅតែបន្តកើតមានម្តងហើយម្តងទៀតជាមួយនឹងការបញ្ជូនសារអេឡិចត្រូនិក(អ៊ីម៉ែល) គេអាចបញ្ជូនរបាយការណ៍នោះ តាមរយៈម៉ាស៊ីនហ្វាក់ទៅកាន់លេខ៖ +41 22 917 90 11.

**តើមានអ្វីកើតឡើងបន្ទាប់ពីការបញ្ជូនរបាយការណ៍អង្គការសង្គមស៊ីវិល?**[6]

- នៅពេលបានទទួលរបាយការណ៍របស់អង្គការសង្គមស៊ីវិលហើយ ការិយាល័យOHCHRនឹងត្រូវពិនិត្យមើលដើម្បីធ្វើឲ្យប្រាកដថារបាយការណ៍នោះស្របឬមិនស្របតាមគោលការណ៍ណែនាំផ្នែកបច្ចេកទេសរបស់ខ្លួន។[7] ប្រសិនជាស្របហើយ របាយការណ៍នោះនឹងត្រូវបានដាក់បង្ហោះលើគេហទំព័រ UPR របស់ការិយាល័យ OHCHR។[8]
- បន្ទាប់មក ការិយាល័យ OHCHR ត្រូវជ្រើសសម្រាំងយកព័ត៌មានពីគ្រប់របាយការណ៍ទាំងអស់ ដែលខ្លួនបានទទួលពីអង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធដទៃទៀត ដើម្បីធ្វើរបាយការណ៍សង្ខេបរបស់ខ្លួន អំពីព័ត៌មានរបស់អ្នកពាក់ព័ន្ធ។

រដ្ឋសមាជិកទាំងឡាយរបស់ អ.ស.ប អាចគាំទ្របញ្ហា ឬអនុសាសន៍មួយចំនួន ដែលបានលើកឡើងក្នុងកម្រងព័ត៌មាន ហើយបញ្ចូលវាទៅក្នុងសេចក្តីថ្លែងការណ៍ផ្ទាល់របស់ខ្លួន។ នេះគឺជាឱកាសដ៏អស្ចារ្យមួយ សំរាប់ការចូលរួមរបស់អង្គការសង្គមស៊ីវិល៖ តាមរយៈសកម្មភាពនៃការតស៊ូមតិ និងការបញ្ចុះបញ្ចូល អង្គការសង្គមស៊ីវិល អាចបញ្ចុះបញ្ចូលរដ្ឋផ្សេងៗឲ្យធ្វើអនុសាសន៍ខ្លះ បើមិនបានទាំងអស់ទេ តាមអ្វីដែលខ្លួនបានស្នើសុំ នៅក្នុងអំឡុងពេលពិនិត្យរបាយការណ៍។[9] ការតស៊ូមតិ និងការបញ្ចុះបញ្ចូល ក៏អាចបញ្ជាក់ផងដែរថា រដ្ឋផ្សេងៗយល់ដឹងអំពីទិដ្ឋភាពទាំងមូលនៃបញ្ហាសិទ្ធិមនុស្សនៅក្នុងប្រទេសរបស់ខ្លួន ហើយមិនត្រឹមតែបញ្ហាមួយចំនួន ដែលមើលឃើញច្បាស់ក្រឡែតបំផុតនោះទេ។

អនុសាសន៍ទាំងអស់ ដែលបានធ្វើឡើងដោយរដ្ឋនានា នៅក្នុងអំឡុងពេលនៃការពិនិត្យរបាយការណ៍ បើទោះជានៅពេលក្រោយមក ត្រូវបានទទួលយក ឬត្រូវបានទាត់ចោលក្តី ក៏មាននៅលើរបាយការណ៍របស់ក្រុមការងារដែរ (ដែលគេហៅម៉្យាងទៀតថា របាយការណ៍ស្តីពីលទ្ធផលនៃកិច្ចប្រជុំ UPR) ដែលនិយាយសង្ខេប អំពីកិច្ចសន្ទនាគ្នារវាងសមាជិកក្រុមប្រឹក្សាសិទ្ធិមនុស្ស និងរដ្ឋដែលស្ថិតក្រោមការពិនិត្យរបាយការណ៍។ អាស្រ័យហេតុនេះ អនុសាសន៍ទាំងឡាយ ដែលមានក្នុងរបាយការណ៍របស់អង្គការសង្គមស៊ីវិល អាចត្រូវបានបញ្ចូលដោយផ្ទាល់ទៅក្នុងរបាយការណ៍ស្តីពីលទ្ធផលនៃកិច្ចប្រជុំ UPR ហើយអាចមានឱកាសត្រូវទទួលយកដោយរដ្ឋសាម៉ីនោះ។

---

[6] សំរាប់ការយល់ឃើញរួមនៃជុំ UPR ទាំងមូល សូមមើលគេហទំព័រ៖ http://www.upr-info.org/-UPR-Process-.html

[7] សូមចូលទៅកាន់គេហទំព័រ ៖ http://www.ohchr.org/Documents/HRBodies/UPR/TechnicalGuideEN.pdf

[8] បើលោក/អ្នក ចង់អានរបាយការណ៍ដែលបានដាក់បង្ហោះ សូមចូលទៅកាន់គេហទំព័រ៖ http://www.ohchr.org/EN/HRBodies/UPR/Pages/Documentation.aspx ដែលឯកសារសំរាប់រដ្ឋនីមួយៗត្រូវបានពិនិត្យ អាចមានតាមផ្នែកឬតាមប្រទេសនីមួយៗ។ របាយការណ៍អង្គការសង្គមស៊ីវិលដែលបានចងក្រងស្របតាមគោលការណ៍ណែនាំផ្នែកបច្ចេកទេសរបស់ការិយាល័យOHCHR អាចមាននៅក្រោមលេខចុងទំព័រជាប់នឹងកំណត់សង្ខេបនៃព័ត៌មានរបស់អ្នកពាក់ព័ន្ធ នៅលើគេហទំព័ររបស់ប្រទេសនីមួយៗ។

[9] ដើម្បីស្វែងរកព័ត៌មានច្រើនថែមទៀត អំពីរបៀបធ្វើការបញ្ចុះបញ្ចូល សូមមើលគេហទំព័រ៖ http://www.upr-info.org/-NGOs-.html។

## បញ្ជីត្រួតពិនិត្យ

*សមាសធាតុសំខាន់ៗសំរាប់ការបញ្ជូនបានត្រឹមត្រូវនូវរបាយការណ៍របស់អង្គការសង្គមស៊ីវិល ទៅក្នុងយន្តការ UPR*

- ✓ ច្រើនបំផុត ២.៨១៥ ពាក្យ (ប្រហែលជា៥ទំព័រ) សំរាប់ការបញ្ជូនរបាយការណ៍ជាឯកត្តបុគ្គល និង ៥.៦៣០ ពាក្យ (ប្រហែលជា ១០ទំព័រ) សំរាប់ការបញ្ជូនរបាយការណ៍រួមគ្នា។
- ✓ របាយការណ៍ ត្រូវផ្តោតលើបញ្ហាសិទ្ធិមនុស្សសំខាន់ៗ។
- ✓ ព័ត៌មានស្តីពីស្ថានភាពសិទ្ធិមនុស្សក្នុងអំឡុងពេល ៤ កន្លះចុងក្រោយ ដែលបានរៀបចំឡើងក្រោមចំណងជើងរឿង ដែលបានប្រើក្នុងកំណត់សង្ខេបរបស់ការិយាល័យ OHCHR ស្តីពីព័ត៌មានរបស់អ្នកពាក់ព័ន្ធ។
- ✓ ព័ត៌មានស្តីពីការអនុវត្តអនុសាសន៍ដែលបានទទួលក្នុងរដ្ឋដែលស្ថិតក្រោមការពិនិត្យរបាយការណ៍។
- ✓ បញ្ហាសិទ្ធិមនុស្សនីមួយៗដែលត្រូវលើកក្នុងរបាយការណ៍៖ សេចក្តីថ្លែងការណ៍ទូទៅដែលកំណត់បញ្ហាផ្សេងៗ ឧទា. ដើម្បីបង្ហាញអំពីភាពអាចជឿទុកចិត្តបាននៃអនុសាសន៍ និងសេចក្តីថ្លែងការណ៍ទូទៅ។
- ✓ ព័ត៌មានបំពេញបន្ថែមរបស់អង្គការសង្គមស៊ីវិល – ប៉ុន្តែមិនត្រូវនិយាយច្រំដែលទេ – ព័ត៌មាន អ.ស.ប។ មិនគួរមានការចម្លងយកសេចក្តីពន្យល់ទូទៅរបស់គណៈកម្មាធិការឡើយ ព្រោះថាការិយាល័យOHCHR មានព័ត៌មាននេះរួចហើយ។
- ✓ បញ្ហាត្រូវបានគូសបញ្ជាក់តាមរយៈឧទាហរណ៍ ដែលជាព័ត៌មានដំបូងបង្អស់ ផ្អែកលើបទពិសោធន៍របស់អង្គការសង្គមស៊ីវិល និងមិនសំរាប់តែព័ត៌មានរបស់សារព័ត៌មាននោះទេ។
- ✓ អង្គការសង្គមស៊ីវិល គួរប្រើប្រាស់ភាសាបច្ចេកទេស និងវិជ្ជាជីវៈ ដើម្បីបង្ហាញថាពួកគេដឹងអំពីអ្វីដែលពួកគេបរិយាយ និងនិយាយយោងដល់ស្ថិតិ ទិន្នន័យ និង/ឬករណីជាក់លាក់ក្នុងលេខជើងទំព័រ។ កំណត់សង្ខេបរបស់ការិយាល័យ OHCHR នឹងមិននិយាយពីឯកត្តបុគ្គលដែលបានរៀបរាប់ក្នុងរបាយការណ៍ លើកលែងតែវាគឺជាករណីបដិរូប។
- ✓ អនុសាសន៍របស់អង្គការសង្គមស៊ីវិលជាក់ជូនរដ្ឋសាមី គួរតែប្រើពាក្យពេចន៍ ដែលងាយស្រួលក្នុងការឃ្លាំមើលការអនុវត្តរបស់ពួកគេ។ អនុសាសន៍ជាក់លាក់ និងត្រង់ទិសសកម្មភាព ដែលងាយស្រួលក្នុងការបញ្ចុះបញ្ចូល។
- ✓ របាយការណ៍របស់អង្គការសង្គមស៊ីវិល ត្រូវតែបានបញ្ជូនក្នុងអំឡុងពេលដែលបានកំណត់ (៧ ទៅ ៨ខែ មុនពេលពិនិត្យ)។[10]
- ✓ របាយការណ៍ដែលសរសេរបានត្រឹមត្រូវជាភាសាណាមួយរបស់អង្គការសហប្រជាជាតិ អាចជាភាសាអង់គ្លេស បារាំង ឬអេស្បាញ ដើម្បីធានាថា រដ្ឋច្រើនជាអតិបរមាអាចអានរបាយការណ៍នោះបាន។
- ✓ ការិយាល័យ OHCHR មិនអាចព្រាងឡើងវិញនូវរបាយការណ៍របស់អង្គការសង្គមស៊ីវិលបានឡើយ ដោយសារតែហេតុនេះហើយទើបមិនអាចបញ្ចូលព័ត៌មានក្នុងកំណត់សង្ខេបរបស់ខ្លួន ប្រសិនជាភាសានោះមិនដល់កំរិតស្តង់ដារវិជ្ជាជីវៈ។ សំរាប់អ្នកដែលមិនចេះនិយាយបានរអិលនូវភាសាណាមួយរបស់អង្គការសហប្រជាជាតិ ពួកគេអាចរកអ្នកបកប្រែវិជ្ជាជីវៈ ឲ្យធ្វើការបកប្រែរបាយការណ៍របស់ខ្លួនបាន។

| **សូមទាក់ទងមកការិយាល័យ OHCHR នៅកម្ពុជា** |
|---|
| លោកសំ សុផល មន្ត្រីសិទ្ធិមនុស្ស៖ 012 814 262. Email: ssam@ohchr.org |

[10] សូមចូលទៅកាន់គេហទំព័រ៖ http://www.ohchr.org/EN/HRBodies/UPR/Pages/NewDeadlines.aspx ដើម្បីអានគោលការណ៍ណែនាំជាក់លាក់។